មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

វិចារណកថាព័ត៌មាន- ភ្នំពេញ ថ្ងៃទី១៩ ឧសភា ២០១១

# ម.ស.ម.ក. ថ្កោលទោសចំពោះការវាយប្រហារទៅលើអ្នកស្រលាញ់ភេទដូចគ្នា និង សេចក្តីប្រមាថពីក្រុមប៉ូលីស ខណៈកំពុងរីករាយនឹងការប្រារព្ធកម្មវិធីមោទនភាព

នៅពេលរំលងអធ្រាត្រថ្ងៃអាទិត្យទី១៥ ឧសភា ២០១១ បុគ្គលិក និង ភ្ញៀវរបស់រង្គសាលរ៉េនបូ (Rainbow Bar) ដែលជាកន្លែងមិត្តអ្នកស្រលាញ់ភេទដូចគ្នា នៅលើផ្លូវលេខ១៧២ ខណ្ឌដូនពេញ នៃរាជធានីភ្នំពេញត្រូវបានទទួលរងការធ្វើបាបយ៉ាងធ្ងន់ធ្ងរពីសំណាក់អ្នកជិតខាងដែលបណ្តាលឲ្យមានមនុស្សជាច្រើនរងរបួសយ៉ាងធ្ងន់ធ្ងរ និង បង្ករឲ្យមានការខូចខាតផ្សេងៗទៀតទៅលើរង្គសាល។ រង្គសាលនោះបានបង្កើតនូវកម្មវិធីប្រគួតប្រជែង Drag queen ដែលជាផ្នែកមួយដើម្បីអបអរសាទរកម្មវិធីសប្តាហ៍មោទនភាព ២០១១។ បញ្ហាដែលបារម្ភជាងនេះទៅទៀតគឺបើយោងទៅតាមសាក្សីដែលឃើញហេតុការណ៍នោះបានបញ្ជាក់ថាប៉ូលីសបានបដិសេធធ្វើការអន្តរាគមន៍ដរាបណាពួកគេត្រូវបានបង់ប្រាក់សំណូកចំនួន ៥០០ដុល្លាសហរដ្ឋអាមេរិក។

ការវាយប្រហារបានកើតឡើងអំឡុងពេល កម្មវិធីសប្តាហ៍មោទនភាព២០១១ ដែលរៀបចំឡើងដើម្បីអបអរសាទ និង លើកកម្ពស់ការចេះអត់ឱន និង ភាពចម្រុះនៃភេទ និង យេនឌ័រ។ កម្មវិធីសប្តាហ៍មោទនភាព២០១១ បានបញ្ចប់ប្រកបដោយភាពជោគជ័យនៅក្នុងប្រទេសកម្ពុជា ដោយមានការចូលរួមពីសំណាក់មនុស្សច្រើនជាង១,៣០០នាក់ដែលបង្ហាញនូវការគាំទ្ររបស់ពួកគេ និង បានចូលរួមកម្មវិធីនេះជាចំហរនៅទីក្រុងភ្នំពេញ ខេត្តសៀមរាប និង តំបន់ផ្សេងៗទៀតនៅក្នុងប្រទេស។ នេះសរបង្ហាញយ៉ាងច្បាស់ពីប្រជាប្រិយភាពនៃការប្រារព្ធវិធី និង បង្ហាញថាពលរដ្ឋកម្ពុជាកំពុង ទទួលយកទង្វើរដែលស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ទាំងពីរភេទ អ្នកប្តូរភេទ និង អ្នកមានភេទពីរ ("LGBTI")។

ខណៈដែលការវាយប្រហារនេះ គឺជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ការខកខានរបស់ប៉ូលីសដែលមិនបានបំពេញភារកិច្ចរបស់ខ្លួនដើម្បីធានានូវសុវត្ថិភាព និង សន្តិសុខនៃបុគ្គលិក និង ថៅកែនៅក្នុងរង្គសាល គឺអាចចាត់ទុកថាជាបញ្ហាមួយធ្ងន់ធ្ងរថែមទៀត។ ការមិនបានបំពេញភារកិច្ចរបស់ប៉ូលីសក្នុងការធ្វើអន្តរាគមន៍ និង ដើម្បីចាប់ជនល្មើសទៅតាមការស្នើសូម សរឲ្យឃើញនូវភាពព្រងើយកន្តើយហើយដែលធ្ងន់ធ្ងរជាងនេះនោះគឺទង្វើរនេះបញ្ជាក់ពីការយល់ព្រមពីសំណាក់ប៉ូលីសអោយមាន

ការវាយប្រហារ និង ការជម្រុញឲ្យមានការរើសអើងកាន់តែខ្លាំងនៅក្នុងសង្គម។ ការមិនបានបំពេញភារៈកិច្ចរបស់ប៉ូលីសគឺទំនងជម្រុញបន្ថែមឲ្យមានការវាប្រហារហើយនឹងធ្វើបាបផ្នែកផ្លូវអារម្មណ៍របស់អ្នកដែលស្រលាញ់ភេទដូចគ្នា និង អ្នកប្តូរភេទ។

**ឆ្លើយតបចំពោះការវាយប្រហារប្រកបដោយអំពើហិង្សាលើរង្គសាលរ៉េនបូ (Rainbow Bar ) នេះ លោក អ៊ូ វីរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យ និង មិនមាននិន្នាការនយោបាយ ដែលធ្វើការដើម្បីលើកកម្ពស់និង ការពារលិទ្ធិប្រជាធិបតេយ្យ និង គោរពសិទ្ធិមនុស្សនៅប្រទេសកម្ពុជាបានមានប្រសាសន៍ថា៖**

"នេះជាការវាយប្រហារគួរឲ្យតក់ស្លុត និង មិនអាចទទួលយកបានទៅលើមនុស្សដែលមិនមានកំហុសអ្វីសោះ ហើយខណៈពួកគាត់កំពុងតែរីករាយ និង សប្បាយប្រារព្ធកម្មវិធីសប្តាហ៍មោទនភាព ២០១១។ ម.ស.ម.ក. ផ្តន្ទាទោសសកម្មភាពដ៏គួរឲ្យស្អប់ខ្ពើម និង កំសាកនេះប៉ុន្តែអបអរសាទរដល់បុគ្គលិករង្គសាលរ៉េនបូ (Rainbow Bar) ដោយមិនមានការតក់ស្លុតដែលត្រូវបានបំភ័យ និង ក្លាហានក្នុងការបន្តការប្រារព្ធកម្មវិធីសប្តាហ៍មោទនភាពរបស់ពួកគេបន្ទាប់ពីការវាប្រហារនេះ។ ទោះជាយ៉ាងណាក៏ដោយ យើងមានការចាប់អារម្មយ៉ាងខ្លាំងចំពោះការរាយការណ៍ពីកង្វះខាតអន្តរាគមន៍ពីសំណាក់ប៉ូលីស និង ជម្រុញឲ្យមានការស៊ើបអង្កេតឲ្យបានត្រឹមត្រូវទៅលើការវាយប្រហារនេះ។ ភាពល្ងង់ខ្លៅនៃក្រុមមនុស្សដែលបានប្រព្រឹត្តអំពើទុច្ចរិតនេះគឺជារឿងមួយប៉ុន្តែភាពធ្វេសប្រហែសទាំងស្រុងពីសំណាក់អាជ្ញាធរគួបផ្សំជាបញ្ហាដែលត្រូវយកចិត្តទុកដាក់"។

**សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង លោក អ៊ូ វីរៈ (តាមរយៈទូរស័ព្ទលេខ +៨៥៥ (0) ១២ ៤០ ៤០ ៥១ ឬ អ៊ីម៉ែល ouvirak@cchrcambodia.org )**

*គម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រនៃម.ស.ម.ក. ៖ "សង្គមដែលមានភាពជឿនលឿនត្រូវបានពង្រឹងដោយភាពចម្រុះគ្នា"*